# ជនជាតិដើមភាគតិចនៅក្នុងការអនុវត្តការរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីធ្លីដទៃទៀត

## សេចក្តីប្រកាសផ្តល់ជំនួយឥតសំណងខ្នាតតូចដល់សហគមន៍និងក្រុមជនជាតិដើមភាគតិច

**កម្មវិធីកិច្ចសន្យាអាកាសធាតុរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ** (UNDP Climate Promise) **និង កម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោករបស់កម្មវិធីអភិវឌ្ឍសហប្រជាជាតិ** (GEF SGP UNDP)

ខែកញ្ញា ឆ្នាំ ២០២៣



## ១.០ សេចក្តីផ្តើម

ឯកសារនេះ គឺជាឯកសារណែនាំសម្រាប់អង្គការជនជាតិដើមភាគតិច (IPOs) អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក (LNGOs) និងអង្គការសហគមន៍ (CBOs) ដែលចាប់អារម្មណ៍ចង់ចូលរួមក្នុងការដាក់សំណើអនុវត្តគម្រោង ក្រោមគំនិតផ្តួចផ្តើមកិច្ចសន្យាអាកាសធាតុ (Climate Promise) របស់ UNDP ផ្នែកការងារព្រៃឈើ ដីធ្លី និងធម្មជាតិ (FLN)។ ឯកសារនេះបង្ហាញពីគំនិតផ្តួចផ្តើមនេះ ក្នុងបរិបទរបស់ប្រទេស និងការងារតាមប្រធានបទជាក់លាក់ សម្រាប់ឱកាសទទួលបានជំនួយខ្នាតតូច និងដំណើរការដែលចាំបាច់សម្រាប់ដាក់សំណើ មកកាន់គម្រោង។

ជំនួយឥតសំណងសម្រាប់ជនជាតិដើមភាគតិច (IPs) អនុវត្តក្រោមគំនិតផ្តួចផ្តើមកិច្ចសន្យាអាកាសធាតុ របស់ UNDP នេះ ត្រូវបានធ្វើឡើងដោយកម្មវិធីផ្តល់ជំនួយខ្នាតតូចនៃកម្មវិធីបរិស្ថានពិភពលោករបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (ហៅកាត់ថា GEF SGP UNDP) ដែលបានដំណើរការនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ២០០៤ មក។ កម្មវិធីផ្តល់ជំនួយនេះ ត្រូវបានរៀបចំឡើងផ្តោតលើក្រុមជនជាតិភាគតិចនៅក្នុងប្រទេសនេះ និងមានផ្តល់ជំនួយដល់អង្គការជនជាតិដើមភាគតិច អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ឬអង្គការសហគមន៍ ដែលធ្វើការងារផ្ទាល់ជាមួយជនជាតិដើមភាគតិច និងសហគមន៍ជនជាតិដើមភាគតិច ក្នុងការចូលរួមអនុវត្តការរួមចំណែករបស់ជាតិស្តីពីការប្រែប្រួលអាកាសធាតុ (ហៅកាត់ថា NDC) ក្នុងវិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីធ្លីដទៃទៀត (FOLU)។

## ២.០ សារៈប្រយោជន៍

### ២.១ កិច្ចព្រមព្រៀងទីក្រុងប៉ារីស និងការរួមចំណែករបស់ជាតិស្តីពីការប្រែប្រួលអាកាសធាតុ (ហៅកាត់ថា NDC)

កិច្ចព្រមព្រៀងទីក្រុងប៉ារីស គឺជាសន្ធិសញ្ញាអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលជាលិខិតតុបករណ៍ចងកាតព្វកិច្ចច្បាប់។ កិច្ចព្រមព្រៀងនេះត្រូវបានអនុម័តដោយភាគីចំនួន ១៩៦ ដែលបានចូលរួមក្នុងកិច្ចប្រជុំ UNFCCC COP ២១ ក្នុងទីក្រុងប៉ារីស ឆ្នាំ ២០១៥។ កិច្ចព្រមព្រៀងនេះ មានគោលដៅកំហិតការឡើងកំដៅផែនដីឱ្យនៅក្រោម ២ អង្សាសេ ល្អបំផុតនៅត្រឹម ១,៥ អង្សាសេ ធៀបនឹងកម្រិតមុនឧស្សាហកម្ម។ ការរួមចំណែករបស់ជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (NDCs) បង្ហាញពីសកម្មភាពកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ភាគីនីមួយៗនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ត្រូវរៀបចំរបាយការណ៍ស្តីពីការរួមចំណែករបស់ជាតិ និងធ្វើបច្ចុប្បន្នភាពរបាយការណ៍នេះរៀងរាល់ ៥ ឆ្នាំម្តង។

### ២.២ ជនជាតិដើមភាគតិចនៅទូទាំងសកលលោក

ជនជាតិដើមភាគតិចបាន និងកំពុងតស៊ូមតិ ដើម្បីឱ្យមានការទទួលស្គាល់សិទ្ធិ ចំណេះដឹង និងទម្លាប់បែបប្រពៃណី ដែលពួកគេបន្តអនុវត្តរាប់ទសវត្សរ៍មកហើយ នៅក្នុងការចរចាអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងដើម្បី

បញ្ចូលពួកគេទៅក្នុងផែនការ និងកិច្ចព្រមព្រៀងនៅថ្នាក់ជាតិ និងអន្តរជាតិ ពាក់ព័ន្ធនឹងការកាត់បន្ថយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ ដោយសារការសម្របសម្រួលក្នុងចំណោមជនជាតិដើមភាគតិចដែលជាម្ចាស់សិទ្ធិតំណាងរបស់ពួកគេ ក៏ដូចជាសម្ព័ន្ធភាពមកពីជុំវិញពិភពលោក កាន់តែមានភាពល្អប្រសើរជាបន្តបន្ទាប់ សេចក្តីសម្រេចនៃសន្និសីទភាគីនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ជាពិសេស កិច្ចព្រមព្រៀងទីក្រុងប៉ារីស[1] បានបញ្ចូលការលើកឡើងសំខាន់ៗអំពីសិទ្ធិ ចំណេះដឹងជាប្រពៃណី និងតួនាទីរបស់ជនជាតិដើមភាគតិច ក្នុងការកាត់បន្ថយ និងការបន្សុំាទៅនឹងអាកាសធាតុ ហើយវេទិការសម្រាប់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច (ហៅកាត់ថា LCIPP) ត្រូវបានបង្កើតឡើង ដើម្បីបន្តផ្តល់ឱកាស និងពង្រឹងការចូលរួមរបស់ពួកគេ ក្នុងដំណើរការ UNFCCC។[2]

## ៣.0 កម្មវិធីកិច្ចសន្យាអាកាសធាតុ របស់ UNDP

ជាផ្នែកមួយនៃកិច្ចប្រជុំកំពូលស្តីពីសកម្មភាពអាកាសធាតុនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ កាលពីឆ្នាំ ២០១៩ UNDP សន្យាថានឹងផ្តល់ការគាំទ្រដល់ប្រទេសយ៉ាងហោចណាស់ចំនួន ១០០ ក្នុងការរៀបចំរបាយការណ៍ NDCs របស់ខ្លួនឱ្យបានកាន់តែប្រសើរ មុនកិច្ចប្រជុំ UNFCCC COP២៦។ ការសន្យានេះបានក្លាយខ្លួនជាកម្មវិធីកិច្ចសន្យាអាកាសធាតុរបស់ UNDP ដែលបច្ចុប្បន្ន គឺជាកម្មវិធីធំបំផុតមួយក្នុងសកលលោក ដែលផ្តល់ការគាំទ្រដល់ប្រទេសនានាក្នុងការរៀបចំរបាយការណ៍ NDCs ក្រោមក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ គំនិតផ្តួចផ្តើមនេះបានផ្តល់ការគាំទ្រដល់ប្រទេសចំនួន ១២០ ដើម្បីរួមចំណែកបង្កើនមហិច្ឆតាកាត់បន្ថយ និងបន្សុំាទៅនឹងអាកាសធាតុ ដោយមានការសហការជាមួយដៃគូជាង ៣៥ ហើយក៏ជាគំនិតផ្តួចផ្តើមដ៏ធំមួយ ដែលរួមចំណែកដល់ការកសាងភាពជាដៃគូ ក្នុងការរៀបចំរបាយការណ៍ NDC ផងដែរ។ ជោគជ័យនេះ នាំឱ្យប្រទេសជាច្រើនមានតម្រូវការលើសលុប ចង់ទទួលបានការបន្តការគាំទ្រពី UNDP ក្នុងដំណាក់កាលអនុវត្តបន្តទៀត ពោលគឺដំណាក់កាលប្រែក្លាយការសន្យារបស់បណ្តាប្រទេស ទៅជាសកម្មភាពអនុវត្តជាក់ស្តែង។

ជាការឆ្លើយតប ក្នុងកិច្ចប្រជុំ COP២៦ នាយក UNDP បានប្រកាសដាក់ឱ្យអនុវត្តនៅជំហានបន្ទាប់នៃកម្មវិធីកិច្ចសន្យាអាកាសធាតុ ក្រោមពាក្យស្លោក "ចេញពីការសន្យាទៅជាផលជះ" ក្នុងគោលដៅរួម ដើម្បីជួយដល់ប្រទេសយ៉ាងហោចណាស់ ១០០ ប្រែក្លាយការសន្យារបស់ខ្លួន ទៅជាសកម្មភាពឆ្ពោះទៅរកមាគ៌ាអភិវឌ្ឍន៍ដោយចីរភាព ដែលមានការបំភាយឧស្ម័នផ្ទះកញ្ចក់សូន្យ (net-zero) និងធន់ទៅនឹងអាកាសធាតុ។ ក្នុងនាមជាឯកសារគោល ដែលមានការគាំទ្រពីកម្រិតនយោបាយ និងដែលបង្ហាញពីការវិនិយោគលើវិស័យសំខាន់ៗ ដើម្បីជំរុញការអភិវឌ្ឍន៍ដោយចីរភាព របាយការណ៍ NDCs ផ្តល់នូវឱកាស ដើម្បីសម្រេចសក្តានុពលក្នុងការធ្វើអន្តរកាលប្រកបដោយយុត្តិធម៌។ ផ្អែកលើលទ្ធផលបទ

---

[1] កិច្ចព្រមព្រៀងប៉ារីស គឺជាសន្ធិសញ្ញាអន្តរជាតិចងកាតព្វកិច្ចតាមផ្លូវច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ អនុម័តដោយភាគីចំនួន ១៩៦ នៃអនុសញ្ញា UNFCCC ក្នុងអំឡុងកិច្ចប្រជុំ COP ២១ នៅទីក្រុងប៉ារីស កាលពីឆ្នាំ ២០១៥។ គោលដៅចម្បងនៃកិច្ចព្រមព្រៀងនេះ គឺកំហិតការឡើងកម្តៅផែនដីឱ្យនៅក្រោម ២ អង្សាសេ ល្អបំផុតត្រឹម ១,៥ អង្សាសេធៀបនឹងកម្រិតមុនឧស្សាហកម្ម។

[2] LCIPP ត្រូវបានបង្កើតឡើងដោយមាត្រា ១៣៦ នៃកិច្ចព្រមព្រៀងប៉ារីស និងក្រុមការងារសម្របសម្រួល LCIPP ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៨ ដែលជាស្ថាប័នមួយស្ថិតក្រោមចំណុះ UNFCCC ដែលមានតួនាទីផ្តល់ដំបូន្មាន ជាតុចូលបច្ចេកទេស និងជំនាញឯកទេស ដើម្បីលើកកម្ពស់ការអនុវត្តអនុសញ្ញានេះ និងកិច្ចព្រមព្រៀងប៉ារីស។

ពិសោធន៍ និងសមិទ្ធផលដែលសម្រេចបាននៅក្នុងដំណាក់កាលទី ១ និងក្នុងនាមជាកម្មវិធីដ៏សំខាន់មួយដែលរួមចំណែកដល់ការកសាងភាពជាដៃគូ ក្នុងការរៀបចំ NDC គំនិតផ្តួចផ្តើមនេះផ្តល់ការគាំទ្រដល់ប្រទេសនានាលើសសរស្តម្ភចំនួន ៣ ដែលផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមកៈ

**វិសាលភាព និងល្បឿន** – ប្រទេសនានាមានយន្តការអភិបាលកិច្ច និងយន្តការហិរញ្ញប្បទាន ដែលមានលក្ខណៈបរិយាបន្ន និងឆ្លើយតបចំពោះយេនឌ័រ ដើម្បីផ្តល់លទ្ធភាពឱ្យគេអាចសម្រេចចំណុចដៅ NDC នៅតាមវិស័យនានា និងអាចតាមដានពីវឌ្ឍនភាពនៃចំណុចដៅទាំងនេះ។

**ពង្រីកមហិច្ឆតា** – NDCs រួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់មាគ៌ារយៈពេលវែង ស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងគោលដៅអភិវឌ្ឍន៍ដោយចីរភាព។

**បរិយាបន្នយូរអង្វែង** – តួអង្គនានាទទួលបានភាពអង់អាចរួមគ្នា ក្នុងការជំរុញសកម្មភាពអាកាសធាតុ និងធានាឱ្យមានការចូលរួមពីកម្លាំងសរុបនៅក្នុងសង្គម។

គិតត្រឹមខែកក្កដា ឆ្នាំ ២០២២ ប្រទេសដែលចូលរួមនៅក្នុងគំនិតផ្តួចផ្តើមកិច្ចសន្យាអាកាសធាតុ ចំនួន ១០០ បានដាក់របាយការណ៍ NDCs ដែលត្រូវបានរៀបចំកាន់តែប្រសើរ ជូន UNFCCC ស្មើនឹង ២២,២១% នៃការបំភាយឧស្ម័នផ្ទះកញ្ចក់នៅក្នុងសកលលោក និង ៨៤% នៃប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងចំណោមរបាយការណ៍ទាំងនេះ

- របាយការណ៍ ៨៩% មានមហិច្ឆតាកាត់បន្ថយការប្រែប្រួលអាកាសធាតុកាន់តែច្រើនជាងមុន ដែលក្នុងនោះរបាយការណ៍ ទាំង ១០០% សុទ្ធតែបានបញ្ចូលចំណុចដៅពាក់ព័ន្ធនឹងវិស័យថាមពល
- របាយការណ៍ ៩៥% មានមហិច្ឆតាបន្សាំកាន់តែច្រើនជាងមុន ស្របតាមផែនការបន្សាំនៅថ្នាក់ជាតិ
- របាយការណ៍ ៩៦% បានបញ្ចូលយេនឌ័រ និង ៩៧% បានបញ្ចូលយុវជនដែលមាននេះជាការឆ្លុះបញ្ចាំងពីការចូលរួមយ៉ាងទូលំទូលាយពីសំណាក់តួអង្គពាក់ព័ន្ធនានា។

## ៣.១ ផ្នែកការងារដែលផ្តោតលើព្រៃឈើ ដីធ្លី និងធម្មជាតិ

កម្មវិធីផ្តល់ជំនួយខ្នាតតូចនេះ គឺជាការរួមវិភាគទានដែលក្រសួងបរិស្ថាន ស្បៀង និងកិច្ចការជនបទរបស់ចក្រភពអង់គ្លេស (DEFRA) ផ្តល់ដល់កម្មវិធីកិច្ចសន្យាអាកាសធាតុ របស់ UNDP។ កម្មវិធីផ្តល់ជំនួយនេះមានគោលបំណងចង់ឱ្យប្រទេសដែលទទួលជំនួយ បង្ហាញពីមហិច្ឆតាកាន់តែខ្ពស់ពាក់ព័ន្ធនឹងធម្មជាតិ ក្នុងរបាយការណ៍ NDCs តាមរយៈការវាយតម្លៃលើកម្រិតដែលធម្មជាតិអាចរួមចំណែកសម្រេចចំណុចដៅអាកាសធាតុ និងការរៀបចំផែនការ និងគោលនយោបាយដែលចាំបាច់សម្រាប់ធ្វើការអនុវត្ត។ លើសពីនេះ គេរំពឹងថាការរួមចំណែកនេះ ក៏នឹងជួយដល់បណ្តាប្រទេសទទួល

ជំនួយ ក្នុងការអនុវត្តតាមអ្វីដែលខ្លួនបានសន្យា ក្នុងសេចក្តីប្រកាសស្តីពីព្រៃឈើ និងការប្រើប្រាស់ដីធ្លី ដែលថ្លែងដោយថ្នាក់ដឹកនាំ នៅទីក្រុង Glasgow។[3]

# ៤.0 បរិបទកម្ពុជា

ស្របតាមលក្ខខណ្ឌតម្រូវឱ្យផ្សព្វផ្សាយពីសកម្មភាពកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងបន្ស៊ាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ របាយការណ៍ NDC បច្ចុប្បន្នភាពឆ្នាំ ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវចំណុចដៅប្រកបដោយមហិច្ឆតា ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ជារួមឱ្យបាន ៤២% ត្រឹមឆ្នាំ ២០៣០។ កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់សំខាន់ៗត្រឹមឆ្នាំ ២០៣០ នឹងមានប្រភពចេញពីវិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីធ្លីដទៃទៀត ដែលនឹងមានការខិតខំសម្រេចឱ្យបាននូវការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់កន្លងមកឱ្យបាន ៥០% (ស្មើនឹង ៧៦,៣ លាន $tCO_2e$) ពីការបាត់បង់ព្រៃឈើ។ នៅក្នុងយុទ្ធសាស្ត្រស្តីពីអព្យាក្រឹតកាបូនរយៈពេលវែង (LTS4CN) ដែលត្រូវបានដាក់កាលពីខែធ្នូ ឆ្នាំ ២០២១ គេរំពឹងថាវិស័យ FOLU និងសម្រេចបាននូវអព្យាក្រឹតកាបូនចាប់ពីឆ្នាំ ២០៣១ តទៅ និងមានការសម្រេចបានការបំភាយឧស្ម័នផ្ទះកញ្ចក់សូន្យពីការបាត់បង់ព្រៃឈើត្រឹមឆ្នាំ ២០៤៥។ យុទ្ធសាស្ត្រ LTS4CN ក៏លើកឡើងផងដែរថា វិស័យ FOLU និងក្លាយជាអាងកាបូនសុទ្ធដែលស្តុកកាបូនចំនួន ៥០ មេកាតោន $CO_2e$ ត្រឹមឆ្នាំ ២០៥០។ ដូច្នេះ គេរំពឹងថានេះគឺជាវិស័យដ៏សំខាន់មួយ ដើម្បីកាត់កងការបំភាយឧស្ម័នផ្ទះកញ្ចក់ពីវិស័យថាមពល កសិកម្ម ដំណើរការឧស្សាហកម្ម ការប្រើប្រាស់ផលិតផល (IPPU) និងវិស័យសំណល់។

ការកំណត់មហិច្ឆតានៅក្នុង NDC ២០២០ និង LTS4CN ធ្វើឡើង ផ្អែកតាមវឌ្ឍនភាព ដែលកម្មវិធីសម្រេចបានក្នុងការអនុវត្តន៍រេដបូក និងការបំពេញតាមក្របខ័ណ្ឌរេដបូក Warsaw ដូចជា៖ ការរៀបចំយុទ្ធសាស្ត្រជាតិរេដបូក (២០១៧) ប្រព័ន្ធតាមដានព្រៃឈើជាតិ (NFMS) (២០១៧) កម្រិតយោងព្រៃឈើ (FRL) (២០១៧, ២០២១) និងព័ត៌មានសង្ខេប (SoI) (២០១៩) រួមទាំងឧបសម្ព័ន្ធបច្ចេកទេសរេដបូក (២០២០)។ លើសពីនេះ ផែនការសកម្មភាព និងវិនិយោគរេដបូក ដែលទទួលបានការគាំទ្រកាលពីឆ្នាំ ២០២១ បានព្យាករថាត្រូវការចំណាយថវិកា ១៨៦ លានដុល្លារ ត្រឹមឆ្នាំ ២០៣១ ដើម្បីអនុវត្តគោលនយោបាយ និងវិធានការនានា ដែលត្រូវបានដាក់ចេញ ក្នុងយុទ្ធសាស្ត្រជាតិរេដបូក។

ដោយឡែកពាក់ព័ន្ធនឹងជនជាតិដើមភាគតិចវិញ រដ្ឋធម្មនុញ្ញកម្ពុជាទទួលស្គាល់ថា ពលរដ្ឋកម្ពុជា រាប់បញ្ចូលទាំងជនជាតិដើមភាគតិចទាំងអស់ ដែលត្រូវបានលើកឡើងក្នុងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិចមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដោយមិនប្រកាន់ពូជសាសន៍ពណ៌សម្បុរ និងជាតិកំណើតនោះឡើយ។ NDC បច្ចុប្បន្នភាព ឆ្នាំ ២០២០ របស់រាជរដ្ឋាភិបាលបន្តគូសបញ្ជាក់ពីការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់សិទ្ធិរបស់ជនជាតិដើមភាគតិច ជាពិសេស ពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លី ក្នុងអំឡុងពេលនៃការអនុវត្តវិធានការកាត់បន្ថយការបំភាយឧស្ម័នផ្ទះ

[3] https://webarchive.nationalarchives.gov.uk/ukgwa/20230418175226/https://ukcop26.org/glasgow-leaders-declaration-on-forests-and-land-use/

កញ្ចក់ ក្នុងវិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីធ្លីដទៃទៀត។ លើសពីនេះ ការគោរពចំណេះដឹងប្រពៃណីរបស់ជនជាតិដើមភាគតិចមានសារៈសំខាន់ ដើម្បីឱ្យគេអាចយល់ពីមុខរបរចិញ្ចឹមជីវិត និងវប្បធម៌ប្រពៃណីរបស់ពួកគេ។ ដូច្នេះ វាជាសមាសភាគដ៏សំខាន់ ដើម្បីការពារសិទ្ធិរបស់ជនជាតិដើមភាគតិចទាំងនេះ។

កាលពីឆ្នាំ ២០១៩ អង្គការ Asia Indigenous Peoples Pact (AIPP) បានសហការជាមួយ UNDP តាមរយៈកម្មវិធី UN-REDD និងកម្មវិធី Forest Peoples Programme ធ្វើការសិក្សាមួយ ដើម្បីរំលេចឱ្យឃើញ ថាតើសិទ្ធិ តួនាទី ព្រមទាំងចំណេះដឹងរបស់ជនជាតិដើមភាគតិច ជាបុរស ស្ត្រី យុវជន និងជនមានពិការភាព ត្រូវបានលើកយកមកបញ្ចូលក្នុងគោលនយោបាយ និងផែនការអាកាសធាតុនៅថ្នាក់ជាតិ ដូចជា NDCs[4] យុទ្ធសាស្ត្ររេដបូក ផែនការបន្សាំនៅថ្នាក់ជាតិ និងច្បាប់បរិស្ថានដែលពាក់ព័ន្ធនៅក្នុងតំបន់អាស៊ីយ៉ាងដូចម្ដេចខ្លះ។ លទ្ធផលនៃការសិក្សានេះត្រូវបានប្រមូលចងក្រងដាក់ក្នុងរបាយការណ៍នៅកម្រិតប្រទេសចំនួន ១០[5] និងរបាយការណ៍ថ្នាក់តំបន់[6] ដែលបូកសរុប និងសំយោគលទ្ធផលរកឃើញ និងអនុសាសន៍ដែលទាញចេញពីរបាយការណ៍របស់ប្រទេសទាំង ១០ នេះ។ ឯកសារណែនាំសម្រាប់កម្ពុជា ត្រូវបានរៀបចំឡើង ផ្អែកលើរបាយការណ៍សំយោគខាងលើនេះ និងមានគោលបំណងជំរុញការអនុវត្តអនុសាសន៍ដែលបានពីរបាយការណ៍កម្ពុជា តាមរយៈកម្មវិធីផ្ដល់ជំនួយក្រោមគំនិតផ្ដួចផ្ដើមកិច្ចសន្យាអាកាសធាតុរបស់ UNDP ជាពិសេស ផ្នែកការងារ FLN នៃគំនិតផ្ដួចផ្ដើមនេះ។

# ៥.0 គោលបំណងនៃកម្មវិធីផ្ដល់ជំនួយដល់ជនជាតិដើមភាគតិច

កម្មវិធីផ្ដល់ជំនួយនេះមានគោលបំណង៖

១. ពង្រឹងតួនាទី និងការចូលរួមរបស់ជនជាតិដើមភាគតិច ជាពិសេសស្ត្រី និងយុវជន ក្នុងការអនុវត្តចំណុចដៅសម្រាប់វិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីធ្លីផ្សេងទៀត ដូចដែលត្រូវបានកំណត់នៅក្នុងការរួមចំណែករបស់ជាតិ។

២. បង្កើន និងពង្រីកវិសាលភាពនៃការអនុវត្តវិធានការព្រៃឈើក្រោមការដឹកនាំរបស់ជនជាតិដើមភាគតិច ដែលនឹងរួមចំណែកដល់ការអនុវត្តការរួមចំណែករបស់ជាតិស្ដីពីការប្រែប្រួលអាកាសធាតុ និងផ្ដល់ជាព័ត៌មានសម្រាប់ការកែសម្រួល NDC ជាបន្ត បន្ទាប់។

---

4 ប្រទេសភាគច្រើនបានធ្វើបច្ចុប្បន្នភាពរបាយការណ៍ NDC របស់ខ្លួននៅមុនកិច្ចប្រជុំ COP២៦ នៅទីក្រុង Glasgow។ សូមចុចតំណភ្ជាប់នេះ ដើម្បីពិនិត្យមើលរបាយការណ៍ចុងក្រោយ៖ https://www4.unfccc.int/sites/NDCStaging/Pages/All.aspx

5 បង់ក្លាដែស កម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា នេប៉ាល់ ហ្វីលីពីន ថៃ និងវៀតណាម។ ការវិភាគសម្រាប់ប្រទេសកម្ពុជាអាចរកបានតាមរយៈ chrome-extension://efaidnbmnnnibpcajpcglclefindmkaj/https://www.climateandforests-undp.org/sites/default/files/resources/NDC%20Mekong%20April2022-digital.pdf

6 https://stories.climateandforests-undp.org/nationally-determined-contributions-in-asia/index.html

## ៦.០ បេក្ខជនដែលមានសិទ្ធិដាក់ពាក្យចូលរួមក្នុងកម្មវិធីនេះ

បេក្ខជនត្រូវតែជា៖

១. អង្គការជនជាតិដើមភាគតិច ឬអង្គការក្រៅរដ្ឋាភិបាលស្រុក ដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ និងដែលមានបទពិសោធន៍ធ្វើការងារផ្ទាល់ជាមួយជនជាតិដើមភាគតិច និងសហគមន៍ជនជាតិដើមភាគតិច ក្នុងការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងព្រៃឈើ និងការប្រើប្រាស់ដីធ្លីដទៃទៀត ឬ

២. អង្គការសហគមន៍ដែលបានចុះបញ្ជីជាអង្គការស្របច្បាប់ ហើយដែលសហគមន៍ភាគច្រើនជាសហគមន៍ជនជាតិដើមភាគតិច។ ឧទាហរណ៍ សហគមន៍ព្រៃឈើ (CF) និងសហគមន៍នេសាទ (CFi) ដែលបានចុះបញ្ជីជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ (CPA) ដែលបានចុះបញ្ជីជាមួយក្រសួងបរិស្ថាន និងសហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃ។

៣. សហគមន៍ជនជាតិដើមភាគតិច និងអង្គការ/សហគមន៍ ដែលពុំទាន់បានចុះបញ្ជីជាផ្លូវការ គេអាចដាក់សំណើរួមគ្នាជាមួយនឹងអង្គការ/សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីរួច។

**លក្ខខណ្ឌតម្រូវពិសេស៖** បេក្ខជនត្រូវផ្តល់ឯកសារបញ្ជាក់ណាមួយក្នុងចំណោមឯកសារខាងក្រោម។ ការពុំបានដាក់ឯកសារណាមួយក្នុងចំណោមឯកសារទាំងនេះ នឹងនាំឱ្យបេក្ខជនលែងមានសិទ្ធិបន្តចូលរួមក្នុងដំណើរការដាក់សំណើគម្រោងនេះបន្តទៀត។

- ឯកសារផ្លូវការចេញដោយក្រសួងអភិវឌ្ឍន៍ជនបទ ដែលទទួលស្គាល់ថាសហគមន៍គោលដៅ ដែលបានដាក់សំណើនេះ គឺជាសហគមន៍ជនជាតិដើមភាគតិចពិតប្រាកដមែន។

**តំបន់គោលដៅ៖** គម្រោងយ៉ាងហោចណាស់ ៣០% ដែលបានបំពេញលក្ខខណ្ឌ ដើម្បីទទួលបានថវិកាគាំទ្រ ត្រូវអនុវត្តដោយស្ត្រី និងយុវជនជាជនជាតិដើមភាគតិច។

## ៧.០ ប្រធានបទ

សំណើត្រូវពាក់ព័ន្ធផ្ទាល់នឹងប្រធានបទមួយ ឬច្រើន ដែលរួមជាមួយបញ្ជីសកម្មភាពអាចអនុវត្តបាន ដូចខាងក្រោម៖

១. **ការរៀបចំលក្ខខណ្ឌអំណោយផល ដើម្បីលើកកម្ពស់ការគោរពសិទ្ធិជនជាតិដើមភាគតិចក្នុងវិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីធ្លីផ្សេងទៀត**

   ក. គាំទ្រដល់ដំណើរការចុះបញ្ជីជនជាតិដើមភាគតិច ដើម្បីពង្រឹងអត្តសញ្ញាណជនជាតិដើមភាគតិច និងការប្រើប្រាស់ដីធ្លីបែបប្រពៃណីរបស់ពួកគេ។

ខ. រួមចំណែកដល់ដំណើរការចុះបញ្ជីដីធ្លី តាមរយៈការរៀបចំផែនទីដែលមានការចូលរួម ដើម្បីកំណត់ព្រំប្រទល់ប្រភេទដីដែលមានការប្រើប្រាស់ផ្សេងៗគ្នា ដូចជា ដីអារក្ខ ដីកសិកម្ម/ដីសម្រាប់ធ្វើកសិកម្មបែបពនេចរ និងសម្រាប់គោលបំណងផ្សេងទៀត។

គ. ប្រមូលចងក្រងឯកសារ និងលើកកម្ពស់ការប្រើប្រាស់ដីធ្លីរបស់ជនជាតិដើមភាគតិច ជាអាថ៌ ការអភិរក្សដី និងទឹក ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការអនុវត្ត ដែលរួមចំណែកដល់ការអនុវត្តការរួមចំណែករបស់ជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

ឃ. សម្របសម្រួលការពិភាក្សាដែលឆ្លើយតបចំពោះយេនឌ័រ រវាងជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ដើម្បីបែងចែកតួនាទី និងការទទួលខុសត្រូវក្នុងសហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ជនជាតិដើមភាគតិច។

ង. បង្កើនសមត្ថភាព ដើម្បីឱ្យសហគមន៍ជនជាតិដើមភាគតិច អាចចូលរួមក្នុងការរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ និងដែលមានការប៉ះពាល់ដល់ជនជាតិដើមភាគតិច ដោយមានការឆ្លើយតបចំពោះយេនឌ័រ។

ច. សម្របសម្រួលការពិភាក្សាផ្លាស់ប្តូរយោបល់ដោយមានការឆ្លើយតបចំពោះយេនឌ័រ រវាងសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន អំពីការពិនិត្យតាមដានព្រៃឈើតាមសហគមន៍ ការអភិរក្ស និងស្តារព្រៃឈើឡើងវិញបែបប្រពៃណី ការធានាមុខរបរចិញ្ចឹមជីវិតប្រភេទផ្សេងៗរបស់ប្រជាជន។

ឆ. ពង្រឹងសមត្ថភាពរបស់ជនជាតិដើមភាគតិច ដូចជាស្ត្រី និងយុវជន ដែលជាជនជាតិដើមភាគតិច ដើម្បីអាចចូលរួម និងផ្តល់ទស្សនៈរបស់គេនៅក្នុងការពិភាក្សា និងការផ្លាស់ប្តូរយោបល់ប្រភេទផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីធ្លីផ្សេងទៀត។

ជ. លើកកម្ពស់ និងសម្របសម្រួលបណ្តាញជនជាតិដើមភាគតិច ដើម្បីរួមចំណែកដល់ការអនុវត្តការរួមចំណែករបស់ជាតិ និងការកំណត់ពីការរួមចំណែករបស់ជាតិថ្មីស្តីពីការប្រែប្រួលអាកាសធាតុ។

ឈ. លើកកម្ពស់ការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចរបស់សហគមន៍ជនជាតិដើមភាគតិច ដើម្បីធានាបាននូវចីរភាពរយៈពេលវែង និងកាត់បន្ថយភាពក្រីក្រប្រកបដោយភាពធន់ ដែលត្រូវបានចាត់ទុកថាជាអាទិភាពមួយរបស់រដ្ឋ។

## ២. សាកល្បងអនុវត្តវិធានការការពារព្រៃឈើ ក្រោមការដឹកនាំរបស់សហគមន៍ជនជាតិដើមភាគតិច

ក. សកម្មភាពស្តារ និងពិនិត្យតាមដានព្រៃឈើនៅតាមសហគមន៍ ក្នុងតំបន់អភិរក្សព្រៃឈើ ដូចជាតំបន់ការពារធម្មជាតិ ព្រៃលិចទឹក និងតំបន់អភិរក្សព្រៃកោងកាង។

ខ. សកម្មភាពគ្រប់គ្រងព្រៃឈើនៅតាមសហគមន៍ ដូចជាការគ្រប់គ្រង និងការប្រើប្រាស់ព្រៃ ដីព្រៃ និងអនុផលព្រៃឈើប្រកបដោយចីរភាព។

គ. បញ្ចូលការការពារសុវត្ថិភាពរេដបូកកម្ពុជា[7] ទៅក្នុងដំណើរការធ្វើផែនការប្រើប្រាស់ដីធ្លី ដើម្បីផ្តល់ព័ត៌មានដែលពាក់ព័ន្ធនានា ដូចជាសិទ្ធិកាន់កាប់ យេនឌ័រ ការចូលរួមរបស់តួអង្គពាក់ព័ន្ធ ជម្លោះ ផល

[7] https://cambodia-redd-safeguards.org/

ប៉ះពាល់បរិស្ថាន។ រៀបចំ និងធ្វើតេស្តសាកល្បងវិធីសាស្ត្រនានា សម្រាប់អនុវត្ត និងតាមដាន របៀបគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធនឹងការការពារសុវត្ថិភាព។

ឃ. រៀបចំ និងធ្វើតេស្តសាកល្បងវិធីសាស្ត្រ ដើម្បីលើកកម្ពស់សិទ្ធិកាន់កាប់ដីព្រៃ តាមរយៈការធ្វើចំណាត់ថ្នាក់ ការបែងចែកតំបន់ ការកំណត់ព្រំប្រទល់ និងការចុះបញ្ជីដីព្រៃ។

ង. រៀបចំ និងធ្វើតេស្តជម្រើសនានា ដើម្បីធ្វើពិពិធកម្មប្រភព មុខរបរចិញ្ចឹមជីវិត ដូចជា កសិរុក្ខកម្ម ប្រព័ន្ធអេកូឡូស៊ីកសិកម្ម និងការគ្រប់គ្រងដីប្រកបដោយចីរភាព។

ច. ពង្រីកវិសាលភាពគំនិតផ្តួចផ្តើមអេកូទេសចរណ៍នៅតាមសហគមន៍ជនជាតិដើមភាគតិច ឱ្យក្លាយជាជម្រើសមួយដែលមិនពឹងអាស្រ័យខ្លាំងពេកលើធនធានព្រៃ និងធនធានដី។

ឆ. អភិវឌ្ឍឧបករណ៍ និងវិធីសាស្ត្ររៀបចំផែនការប្រើប្រាស់ដីសហគមន៍ ដើម្បីបង្កើនទិន្នផលកសិកម្ម និងការឆ្លើយតបចំពោះកសិផលតាមតម្រូវការទីផ្សារ។

## ៨.0 ទីតាំងភូមិសាស្ត្រ

កម្មវិធី GEF SGP UNDP កម្ពុជា សូមអញ្ជើញអង្គការជនជាតិដើមភាគតិច អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអង្គការសហគមន៍ដែលធ្វើការងារផ្ទាល់ជាមួយនឹងសហគមន៍ជនជាតិដើមភាគតិច នៅក្នុងវិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីធ្លីផ្សេងទៀត ក្នុងគ្រប់ភូមិ ឃុំ ស្រុក ខេត្តទាំងអស់ដែលមានជនជាតិដើមភាគតិចរស់នៅក្នុងប្រទេសកម្ពុជា ឱ្យដាក់សំណើគម្រោងពេញលេញ ដើម្បីទទួលបានជំនួយឥតសំណងនេះ។ សូមមើលឧបសម្ព័ន្ធ ១.ខ អំពីបញ្ជីខេត្ត ឃុំលម្អិតដែលមានសហគមន៍ជនជាតិដើមភាគតិចរស់នៅ។ ជំនួយថវិកានឹងផ្តល់ជូនក្នុងលក្ខណៈប្រកួតប្រជែង។

រូបទី ១៖ តំបន់ជនជាតិដើមភាគតិចនៅកម្ពុជា ( Dataset OD Mekong Datahub )




# ៩.0 សកម្មភាព និងការគាំទ្រដែលមិនអាចអនុវត្តបាន

ធនធានដែលផ្តល់តាមរយៈសេចក្តីប្រកាសផ្តល់ជំនួយនេះ មិនអាចយកទៅប្រើប្រាស់សម្រាប់៖

១. បរិក្ខារ រថយន្ត ហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ សាលារៀន ស្ពាន) ។ល។ (លើកលែងតែមានការបញ្ជាក់ហេតុផលត្រឹមត្រូវ)។

២. គម្រោងសម្រាប់តែវិស័យឯកជន។

៣. គម្រោងដែលពុំមានទំនាក់ទំនងជាមួយគោលនយោបាយនៅកម្រិតម៉ាក្រូ/ប្រព័ន្ធរបស់ជាតិ។

៤. ការធ្វើដំណើរឆ្លងប្រទេស។

៥. ថ្នាំកសិកម្មដែលផលិតពីសារធាតុគីមី ដូចជាថ្នាំសម្លាប់ពពួកផ្សិត ថ្នាំសម្លាប់ស្មៅចង្រៃ និងថ្នាំសម្លាប់សត្វល្អិត។

៦. សម្ភារៈប្លាស្ទិកដែលអាចប្រើបានតែមួយដងហើយចោល។

៧. ការដាំដើមឈើ ឬរុក្ខជាតិប្លែកៗ ឬរុក្ខជាតិនាំចូលពីបរទេស ដើម្បីស្តារព្រៃឈើឡើងវិញ។

៨. ចំណាយដទៃទៀតដែលមិនបង្ហាញពីការរួមចំណែកដោយផ្ទាល់ដល់សកម្មភាពគម្រោង។

## ១០.០ រយៈពេល និងកាលវិភាគអនុវត្តបណ្ដោះអាសន្ន

កម្មវិធីផ្ដល់ជំនួយថវិកាដល់ជនជាតិដើមភាគតិចនេះនឹងត្រូវអនុវត្តពីថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០២៥។

## ១១.០ លក្ខណៈវិនិច្ឆ័យ ដើម្បីអាចចូលរួមនៅក្នុងគម្រោងបាន

គំនិតផ្ដួចផ្ដើម SGP ផ្ដល់ជំនួយឥតសំណងខ្នាតតូច ក្នុងទឹកប្រាក់រហូតដល់ ៥០.០០០ ដុល្លារក្នុងមួយគម្រោង។ គម្រោងទាំងអស់គួរៈ

១. ឆ្លើយតបចំពោះប្រធានបទមួយ ឬច្រើនដូចរៀបរាប់ខាងលើ។
២. បង្ហាញពីនិរន្តរភាពរបស់គម្រោង។
៣. មានការចូលរួមពីសហគមន៍ជនជាតិដើមភាគតិច ជាពិសេសស្ត្រី យុវជន និងជនមានពិការភាពនៅគ្រប់ដំណាក់កាលទាំងអស់របស់គម្រោង។
៤. មានបញ្ចូលការរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយសម្រាប់ធ្វើការពិនិត្យតាមដាន ជាពិសេស ការពិនិត្យតាមដាន និងការវាយតម្លៃលើយន្តការការពារសុវត្ថិភាព។
៥. រៀបចំយន្តការ និងការលើកទឹកចិត្ត ដើម្បីឱ្យគម្រោងនៅបន្តមាននិរន្តរភាពក្រោយបញ្ចប់រយៈពេលអនុវត្ត។
៦. រៀបចំយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងឱ្យបានច្បាស់លាស់ដែលនឹង
    ក. ប្រមូលចងក្រងមេរៀនបទពិសោធន៍ពីគម្រោង និងចែករំលែកជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត
    ខ. កំណត់ពីវិធីសាស្ត្រដែលសហគមន៍ដទៃទៀតនៅក្រៅគម្រោងអាចទទួលបានប្រយោជន៍ពីគម្រោងនេះ។

## ១២.០ ដំណើរការដាក់សំណើ និងពិនិត្យលើសំណើ

### ជំហានទី ១៖ ដាក់សំណើគម្រោង (សូមមើលទម្រង់គំរូនៅក្នុងឧបសម្ព័ន្ធទី ១)

សេចក្ដីប្រកាសផ្ដល់ជំនួយឥតសំណងខ្នាតតូចនេះឱ្យដាក់សំណើនេះនឹងដំណើរការចាប់ពីថ្ងៃទី ២០ ខែកញ្ញា ដល់ថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០២៣។ ជាផ្នែកមួយនៃការអំពាវនាវឱ្យដាក់សំណើនេះ នឹងពុំមានការស្នើសុំឯកសារពីគោលគំនិតគម្រោងឡើយ ហើយអ្នកសម្របសម្រួលថ្នាក់ជាតិនឹងរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយ ដើម្បីពន្យល់ពីសារបាន និងលក្ខខណ្ឌតម្រូវដាក់លាក់សម្រាប់សេចក្ដីប្រកាសផ្ដល់ជំនួយនេះ។

អង្គការដែលចាប់អារម្មណ៍ចង់ដាក់សំណើត្រូវបានអញ្ជើញឱ្យផ្ញើសំណើលម្អិត រួមនឹងឧបសម្ព័ន្ធដែលត្រូវបានកំណត់ជាលក្ខខណ្ឌជាភាសាខ្មែរ។ សម្រាប់សំណើដែលដាក់ជាភាសាខ្មែរផង និងភាសាអង់គ្លេសផង សូមធ្វើការបញ្ជាក់ថាសំណើដើមដំបូងត្រូវបានរៀបចំជាភាសាអង់គ្លេស។

សំណើអាចរៀបចំដោយប្រើកុំព្យូទ័រ ឬសរសេរដៃ។ រូបភាព ដូចជារូបថត ក៏អាចប្រើប្រាស់បានដែរក្នុងករណីដែលពាក់ព័ន្ធ ដើម្បីផ្តល់ព័ត៌មានបន្ថែមអំពីសំណើនេះ។ សូមភ្ជាប់ផងដែរនូវឯកសារព័ត៌មានអំពីប្រវត្តិរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ឬអង្គការសហគមន៍ (ឧបសម្ព័ន្ធទី ២) ដែលគួរបន្ថែមលើសំណើគម្រោងក្នុងអំឡុងពេលដាក់សំណើនេះ។

**សំណើដែលដាក់ក្រោយកាលបរិច្ឆេទឈប់ទទួលដែលបានកំណត់នឹងមិនទទួលយកឡើយ។**

សំណើ និងឯកសារគាំទ្រទាំងអស់ត្រូវផ្ញើទៅការិយាល័យ GEF SGP អាគារមេដ្សមណ្ឌលភ្នំពេញ ជាន់ទី ៦ អាគារ ក កែងមហាវិថីសុធារស និងមហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ផ្ញើជូនលោកស្រី ងិន ណាវីរៈ មន្ត្រីជាតិសម្របសម្រួលកម្មវិធី GEF SGP UNDP។ សម្រាប់កម្មវត្ថុសូមសរសេរថា៖ CALL៖ CLIMATE PROMISE FOLU។ សំណៅ និងឧបសម្ព័ន្ធជាសំណៅទន់ ត្រូវផ្ញើឱ្យបានមុនកាលបរិច្ឆេទកំណត់ ទៅកាន់អ៊ីមែល៖ ngin.navirak@undp.org សំណើជាសំណៅរឹងអាចផ្ញើទៅកាន់អាសយដ្ឋានខាងលើ ក្រោយកាលបរិច្ឆេទកំណត់បាន។

## ជំហានទី ២៖ កាលវិភាគសម្រាប់ជ្រើសរើសគម្រោង

គណៈកម្មការជ្រើសរើសនឹងពិនិត្យលើគម្រោងសំណើនានា ចាប់ពីខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ ២០២៣។ ការវាយតម្លៃដែលធ្វើឡើងនៅការិយាល័យ និងតាមតំបន់គោលដៅរបស់គម្រោងដែលបានជ្រើសរើសនីមួយៗ នឹងត្រូវធ្វើឡើងក្នុងរយៈពេលនេះ។ ការសម្រេចចុងក្រោយលើពាក្យសុំដែលទទួលបានជោគជ័យនឹងត្រូវបញ្ចប់មុនចុងខែវិច្ឆិកា ឆ្នាំ ២០២៣។

## ជំហានទី ៣៖ គណៈកម្មការជ្រើសរើសគម្រោង

ការពិនិត្យលើសំណើនានានឹងធ្វើឡើងដោយតម្លាភាព ដោយគណៈកម្មការជ្រើសរើសដែលមានសមាសភាពជាក្រុមអ្នកជំនាញឯករាជ្យនៅក្នុងវិស័យនេះ ឬដោយគណៈកម្មការជាតិដឹកនាំកម្មវិធីជំនួយខ្នាតតូច (NSC)[8]។

- មន្ត្រីជាតិសម្របសម្រួលកម្មវិធី GEF SGP ព្រមទាំងគណៈកម្មការជ្រើសរើសដែលតែងតាំងដោយ NSC និងធ្វើការពិនិត្យបឋមលើសំណើនីមួយៗ
    - គណៈកម្មការជ្រើសរើសមានសមាសភាពជាតំណាងមកពីអង្គការជនជាតិដើមភាគតិច ឬអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ឬអង្គការតាមសហគមន៍ដែលធ្វើការជាមួយជនជាតិដើមភាគតិច[9]
    - តំណាងមកពីកម្មវិធីអាកាសធាតុ និងព្រៃឈើរបស់ UNDP (តំបន់អាស៊ីប៉ាស៊ីហ្វិក)
    - តំណាងមកពី UNDP កម្ពុជា។

[8] គណៈកម្មាធិការដឹកនាំកម្មវិធីនេះថ្នាក់ជាតិមានសមាជិកចំនួន ១២ នាក់ ដែលមានអាណត្តិ ៣ ឆ្នាំម្តង៖ តំណាង ១ រូបមកពីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងក្រសួងអភិវឌ្ឍន៍ជនបទ, ១ រូបមកពី UNDP កម្ពុជា, ៣ រូបមកពីដៃគូអភិវឌ្ឍន៍អន្តរជាតិ (USAID អង្គការ VSO ធនាគារអភិវឌ្ឍន៍អាស៊ី), ១ រូបមកពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ (អង្គការសង្គ្រោះផែនដីកម្ពុជា), ២ រូបមកពីអង្គការក្រៅរដ្ឋាភិបាល/អង្គការតាមសហគមន៍ (វិទ្យាស្ថានអភិវឌ្ឍន៍សហគ្រាស គណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា)។

[9] ដើម្បីចៀសវាងទំនាស់ផលប្រយោជន៍ សូមកត់សម្គាល់ថាតំណាងខាងលើពុំមានសិទ្ធិដាក់សំណើក្រោមកម្មវិធីផ្តល់ជំនួយនេះឡើយ។

- បន្ទាប់មក សំណើនេះនឹងត្រូវដាក់ជូនគណៈកម្មការជាតិដឹកនាំកម្មវិធីជំនួយខ្នាតតូចហើយនឹងមានរៀបចំជាកិច្ចប្រជុំមួយ ដើម្បីសម្រេចចិត្តលើសំណើដែលត្រូវបានជ្រើសរើសបញ្ចូលទៅក្នុងបញ្ជីខ្លី (shortlisted) ដើម្បីចុះវាយតម្លៃដល់ទីវាល និងការធ្វើការវាយតម្លៃលើឯកសារគម្រោងសំណើដែលបានដាក់មក។
- ក្នុងអំឡុងពេលចុះវាយតម្លៃនៅទីវាល គណៈកម្មការជ្រើសរើសអាចតម្រូវឱ្យអង្គការអន្តរការី (IO) ជួយផ្តល់ការគាំទ្រដល់គម្រោង ដែលអង្គការតាមសហគមន៍របស់ជនជាតិដើមភាគតិចដាក់មក ដូចបញ្ជាក់ក្នុងផ្នែក ៦.០៖ បេក្ខជនដែលមានសិទ្ធិដាក់សំណើ។ ប្រសិនបើចាំបាច់ គណៈកម្មការនឹងធ្វើការពិភាក្សាជាមួយសហគមន៍ជនជាតិដើមភាគតិច ពាក់ព័ន្ធនឹងអង្គការអន្តរការីដែលពួកគេមានភាពងាយស្រួលក្នុងការពិភាក្សាជាមួយអន្តរការីអំពីធនធានៈ និងការមានពេល ដើម្បីជួយផ្តល់ការគាំទ្រ, លើកស្នើអង្គការអន្តរការីជូន NSC ដើម្បីផ្តល់ការឯកភាព។
- ផ្អែកលើលទ្ធផលនៃការចុះវាយតម្លៃដល់ទីវាល និងការវាយតម្លៃលើឯកសារគម្រោងសំណើ នឹងមានការរៀបចំកិច្ចប្រជុំរបស់ NSC ដើម្បីពិនិត្យ និងអនុម័តលើសំណើលម្អិត។ អង្គការជនជាតិដើមភាគតិច អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអង្គការតាមសហគមន៍នឹងត្រូវអញ្ជើញឱ្យបង្ហាញ ឬការពារគម្រោងសំណើរបស់ខ្លួន។
- ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំ NSC មន្ត្រីជាតិសម្របសម្រួលកម្មវិធី ឬជំនួយការកម្មវិធី ឬអ្នកគ្រប់គ្រងគម្រោង GEF SGP (UNV) នឹងជូនដំណឹងដល់បេក្ខជនដោយផ្ទាល់ ថាតើសំណើរបស់ពួកគេត្រូវបដិសេធ ឬទទួលយក ព្រមទាំងមានការផ្តល់ជាអនុសាសន៍/លក្ខខណ្ឌ ដើម្បីបង្កើនគុណភាពនៃសំណើ ប្រសិនបើចាំបាច់។

## ជំហានទី ៤៖ លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃលើសំណើគម្រោង

គណៈកម្មការជ្រើសរើសនឹងប្រើប្រាស់លក្ខណៈវិនិច្ឆ័យខាងក្រោម ដើម្បីធ្វើការវាយតម្លៃ។

| លក្ខណៈវិនិច្ឆ័យ | ពិន្ទុ (%) |
| --- | --- |
| ក. លក្ខខណ្ឌតម្រូវជាមូលដ្ឋាន<br>១. អង្គការដែលបានចុះបញ្ជី - អង្គការជនជាតិដើមភាគតិច និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមានបទពិសោធន៍ធ្វើការងារផ្ទាល់ជាមួយសហគមន៍ជនជាតិដើមភាគតិច និងអង្គការជនជាតិដើមភាគតិចតាមសហគមន៍ ដែលបានចុះបញ្ជីមួយក្រសួងមហាផ្ទៃ ឬក្រសួងដទៃទៀត ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ករណីសហគមន៍នេសាទ សហគមន៍ព្រៃឈើ និងសហគមន៍កសិកម្ម និងសហគមន៍តំបន់ការពារធម្មជាតិជាមួយក្រសួងបរិស្ថាន ឬមានបទពិសោធន៍ធ្វើការងារចុះបញ្ជីដីជនជាតិដើមភាគតិចជាសមូហភាពជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ឬក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ (គួរបង្ហាញលិខិតចុះបញ្ជី/ឯកសារពាក់ព័ន្ធ)។<br>២. សារបាន/លក្ខណៈ/សាវតាររបស់អង្គការ ដែលបង្ហាញថាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក/អង្គការតាមសហគមន៍ ដែលមានបទពិសោធន៍ពាក់ព័ន្ធនឹងការងារដែលស្ថិតក្រោមប្រធានបទនៃកម្មវិធី GEF SGP។<br>៣. មានភាពសមស្របជាមួយនឹងគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រនៃកម្មវិធី SGP ដូចដែលត្រូវបានលើកឡើងនៅក្នុងឯកសារជំនួយស្មារតីស្តីពីជនជាតិដើមភាគតិចនៃកម្មវិធី UNDP Climate Promise - GEF SGP FLN។ | មាន/គ្មាន |

| | |
|---|---|
| ៤. បច្ចុប្បន្នមិនមែនជាអ្នកទទួលបានថវិកាជំនួយពីកម្មវិធី UNDP GEF SGP ឬមិនធ្លាប់បានទទួលជំនួយថវិកាពីកម្មវិធី SGP លើសពី ៣ ដង។<br>៥. អង្គការក្រៅរដ្ឋាភិបាល/អង្គការតាមសហគមន៍ ដែលពុំមានឈ្មោះនៅក្នុងបញ្ជីខ្មៅនៃអ្នកដែលទទួលបានថវិកាជំនួយពីកម្មវិធី SGP។<br>៦. ឯកសារផ្លូវការពីក្រសួងអភិវឌ្ឍន៍ជនបទ ដែលទទួលស្គាល់ថាសហគមន៍គោលដៅនៃគម្រោងសំណើនេះ គឺជាសហគមន៍ជនជាតិដើមភាគតិច។ | |
| ខ. សង្គតិភាព និងភាពសមស្របនៃសកម្មភាព លទ្ធផលរំពឹងទុក/ផលជះ និងសូចនាករ | ២០ |
| គ. ការចូលរួម និងការរួមចំណែករបស់សហគមន៍<br>១. សម្រាប់គម្រោងដែលបានខិតខំប្រឹងប្រែងលើសពីធម្មតា ក្នុងការជំរុញការចូលរួមពីសហគមន៍ ឬដែលកំពុងធ្វើតេស្តសាកល្បងលើវិធីសាស្ត្របែបចូលរួមថ្មីៗ គួរមានការសរសេរពីរបីប្រយោគរៀបរាប់ថាតើសហគមន៍បានចូលរួមក្នុងការធ្វើផែនការ ការអនុវត្ត និងការតាមដានគម្រោងយ៉ាងដូចម្តេចកន្លងមក។ ឧទាហរណ៍ គម្រោងបានចងក្រងក្រុមការងារដែលមានសមាសភាពជាសមាជិកសហគមន៍ ដើម្បីតាមដានសកម្មភាពនៅក្នុងតំបន់ការពារធម្មជាតិ ឬបានចូលរួមកែសម្រួលការរចនាបច្ចេកវិទ្យាថាមពលកកើតឡើងវិញ ដើម្បីបំពេញតម្រូវការនៅក្នុងមូលដ្ឋាន។ | ១៥ |
| ឃ. សមត្ថភាពអនុវត្តគម្រោង<br>១. លក្ខណៈរបស់អង្គការ បុគ្គលិក និងថ្នាក់ដឹកនាំ និងយុទ្ធសាស្ត្រតាមដាន និងវាយតម្លៃ។ ក្នុងករណីដែលអង្គការសហគមន៍ត្រូវការការជួយគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ក្នុងការរៀបចំ និងអនុវត្តគម្រោង ចាំបាច់ត្រូវមានការវាយតម្លៃលើសមត្ថភាពអង្គការទាំងពីរ។ | ២០ |
| ង. នវានុវត្តន៍<br>១. គម្រោងព្យាយាមធ្វើតេស្តសាកល្បង ឬដាក់ឱ្យអនុវត្តនូវបច្ចេកទេស ឬបច្ចេកវិទ្យាថ្មីៗ ដែលបង្កើនសមត្ថភាពបន្សាំ ឬសកម្មភាពដែលស្ថិតក្រោមប្រធានបទដទៃទៀតនៃកម្មវិធី GEF ហើយបច្ចេកទេស ឬបច្ចេកវិទ្យាទាំងនេះងាយស្រួលប្រើប្រាស់ និងអនុវត្ត។ | ៥ |
| ច. ផ្តោតលើយេនឌ័រ និងយុវជន<br>១. មានការរៀបរាប់សកម្មភាពបានច្បាស់លាស់ និងមានការវិភាជន៍ថវិកាសមស្រប ដើម្បីលើកកម្ពស់ និងបញ្ចូលស្ត្រី និង/ឬយុវជនយ៉ាងហោចណាស់ ៣០% ទៅក្នុងការអនុវត្ត។ នេះរួមមានការពិចារណាពីតួនាទីរបស់ពួកគេនៅក្នុងគ្រួសារ តួនាទីពាក់ព័ន្ធនឹងសហគមន៍ ក៏ដូចជាការរួមចំណែករបស់ស្ត្រី និងយុវជន ដល់តំបន់គោលដៅរបស់គម្រោង។ | ២០ |
| ឆ. ផលជះលើបរិស្ថាន<br>១. គម្រោងបានរួមចំណែកសម្រេចគោលដៅនៃការរួមចំណែករបស់ជាតិស្តីពីការប្រែប្រួលអាកាសធាតុ សម្រាប់វិស័យព្រៃឈើ និងវិស័យប្រើប្រាស់ដីធ្លីផ្សេងទៀត និងដល់ការអនុវត្តកម្មវិធីរេដបូកជាតិ ដើម្បីធានាថាអន្តរាគមន៍លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានភ្ជាប់ទំនាក់ទំនងជាមួយការការពារបរិស្ថាន។ | ២០ |

| | |
|---|---|
| ជ. ផលជះលើសង្គម និងវប្បធម៌<br>១. សកម្មភាពដែលនាំឱ្យមានការបង្កើនសមត្ថភាពបន្សុំ ឬកាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍ និង/ឬក្រុមគោលដៅរបស់គម្រោង ដោយសារផលប៉ះពាល់អវិជ្ជមាន ដែលកើនឡើងក្នុងកម្រិតដែលអាចសង្កេតដឹងបាន ដោយសារព្រឹត្តិការណ៍ប្រែប្រួលអាកាសធាតុ និងការបំផ្លិចបំផ្លាញដទៃទៀត។ លក្ខណៈវិនិច្ឆ័យទាំងនេះ ក៏នឹងពិនិត្យលើការការពារវប្បធម៌បទដ្ឋាន និងប្រពៃណីរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានផងដែរ។ គម្រោងគួរបង្ហាញពីកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់បរិយាបន្នសង្គម (មិនទុកនរណាម្នាក់ចោល) និងជួយឱ្យក្រុមងាយរងគ្រោះបានទទួលប្រយោជន៍ពីគម្រោងដែលត្រូវបានស្នើឡើង។ | ៥ |
| ឈ. ផលជះមកលើជីវភាពរស់នៅ<br>១. ជម្រើសជីវភាពរស់នៅដែលរួមចំណែកលើកកម្ពស់សន្តិសុខស្បៀង និងបង្កើនចំណូលរបស់អ្នកទទួលផលពីគម្រោង ដោយមិនបង្កគ្រោះថ្នាក់ដល់ធនធានធម្មជាតិ និងបរិស្ថាន ដែលជាពិសេសរួមចំណែកដល់ការសម្រេចការអភិវឌ្ឍន៍ដោយចីរភាព។ | ១៥ |
| ពិន្ទុសរុប | ១២០ |

# ឧបសម្ព័ន្ធទី ១៖ ទម្រង់គំរូនៃសំណើគម្រោង

The GEF Small Grants Programme

## ទម្រង់គំរូនៃសំណើគម្រោង

លក្ខខណ្ឌទូទៅ

នេះ គឺជាទម្រង់គំរូស្តង់ដារសម្រាប់គម្រោងនៃកម្មវិធីផ្តល់ជំនួយខ្នាតតូច ដើម្បីឱ្យអង្គការសង្គមស៊ីវិល និង/ឬអង្គការតាមសហគមន៍យកទៅបំពេញ ដើម្បីដាក់ពាក្យទទួលបានជំនួយថវិកា។ ទម្រង់គំរូនេះអាចយកទៅកែសម្រួល តាមការចាំបាច់ ស្របតាមតម្រូវការ និងបរិបទរបស់ប្រទេស។ ផ្នែកមួយចំនួននៃទម្រង់គំរូនេះត្រូវបំពេញដោយមានការជួយគាំទ្រពីមន្ត្រីជាតិសម្របសម្រួលថ្នាក់ជាតិ និងគណៈកម្មការជាតិដឹកនាំកម្មវិធីនេះ។

